# ទីក្រុងបុរាណអាឡេប្ប៉ូ

អាឡេប្ប៉ូ (Aleppo)គឺជាឈ្មោះនៃទីក្រុងបុរាណមួយក្នុងប្រទេសស៊ីរី ដែលមានន័យថា Halab ក្នុងភាសា អារ៉ាប់។[១] អាឡេប្ប៉ូ គឺជាទីក្រុងធំទីពីរ ក្នុងប្រទេស និងក៏ជាទីក្រុងដែលមានវ័យចំណាស់ជាងគេផងដែរ ដោយមានការតាំងទីរស់នៅតាំងពីសម័យមុនគ.ស. និងជាផ្លូវជួញដូរពាណិជ្ជកម្មតាំងពី២០០០ឆ្នាំ មុនគ.ស.។[២]

ទីក្រុងនេះចាប់ផ្ដើមរីកចម្រើនផ្នែកនយោបាយ និងពាណិជ្ជកម្មខ្លាំងនៅស.វ.ទី១៨ មុនគ.ស. ដែលជារាជធានីនៃអាណាចក្រ យ៉ាមខាដ (Yamkhad)។ ក្រោយមកទៀត នៅក្នុងសម័យ ហេលេនតិច (Hellenistic) ទីក្រុងនេះ គឺជាផ្លូវពាណិជ្ជកម្មដ៏សំខាន់នៅតំបន់សមុទ្រមីឌីទែរ៉ាណេ។[៣] នៅទីក្រុងនេះ គឺមានការគ្រប់គ្រងដោយសម័យកាលជាច្រើនផ្សេងៗគ្នា រួមមាន ហិតិ(Hittites) អាសស៊ើរ(Assyrians) អាកាដេន(Akkadians) ក្រិច(Greeks) រ៉ូម៉ាំង (Romans) អូមាយ៉ាត់(Umayyads) អាយយូប៊ីដ(Ayyubids) ម៉ាមលូក(Mameluks) ប៊ីហ្សីនទីន (Byzantine) និងអូតូម៉ង់(Ottomans) ដែលធ្វើឱ្យទីក្រុងមួយនេះសំបូរទៅដោយអរិយធម៌ និងសិល្បៈចំរុះ។[៤]

នៅឆ្នាំ៦៣៦គ.ស.ទីក្រុងអាឡេប្ប៉ូ ត្រូវបានគ្រប់គ្រងដោយក្រុមអារ៉ាប់ជាង៨០ឆ្នាំ ដែលដឹកនាំដោយ Umayyad Caliph Sulaiman និងបានកសាងសំណង់ព្រះវិហារដ៏ធំមួយផងដែរ។ នៅស.វ.ទី ១០ គ.ស. អាឡេប្ប៉ូបានក្លាយជារាជធានីនៃសន្តតិវង្ស Hamdanid និង

---

[១] https://www.bbc.com/news/world-middle-east-18957096

[២] https://whc.unesco.org/en/list/21

[៣] https://www.bbc.com/news/world-middle-east-18957096

[៤] https://whc.unesco.org/en/list/21

អត្ថបទដោយ៖ អេង តុលា

បន្តដល់ ប៊ីហ្សង់ទីន។ នៅស.វ.ទី ១៦ ទីក្រុងនេះ គឺជាផ្នែកមួយនៃការគ្រប់គ្រងនៃអាណាចក្រ អូតូម៉ង់។[៥]

រចនាសម្ព័ន្ធក្នុងទីក្រុងបុរាណអាឡេប៉ូ គឺមានកំពែងក្រុងជុំវិញដែលកសាងចន្លោះ ស.វ.ទី១២ ដល់១៤គ.ស. ដោយយោធាអារ៉ាប់។ នៅបរិវេណក្នុងក្រុង គឺមានសំណង់ព្រះវិហារ រាជវាំង និងអាគារជាច្រើនទៀត។ ចំពោះសំណង់ស្ថាបត្យកម្មទាំងអស់នោះ គឺស្ថិតនៅចំរុះគ្នាជាច្រើនដែលមានដូចជាសិល្បៈនៃរ៉ូម៉ាំង ក្រិច ពែក្ស ប៊ីហ្សង់ទិន ឃើញមាននៅតាមសំណង់ប្រាសាទនៅក្នុងទីក្រុងបុរាណមួយនេះ ដោយមានសំណង់ សសរខ្ពស់ៗដែលជាអត្តសញ្ញាណសំខាន់នៃសិល្បៈក្រិចបុរាណ ដូចជា រចនាបទ Doric Ionic នឹង Corinthian។[៦] សសរទាំងនោះឃើញនៅតាមប្រាសាទ វិហារ នឹងសំណង់សាធារណៈផ្សេងៗ ដែលរួមបញ្ចូលនូវទេវកថាជាច្រើន និងសំណង់ប្រាសាទដ៏ទៃទៀតដែលកសាងតាមសិល្បៈក្រិចរ៉ូម៉ាំង។ ទីក្រុងបុរាណអាឡេប៉ូ ត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោកក្នុងឆ្នាំ ១៩៨៦ ដើម្បីការពារពីការបំផ្លាញដោយក្រុមអីស្លាមជ្រុលនិយម ដូចនៅតំបន់ទីក្រុងបុរាណផ្សេងៗទៀតដូចនៅ ទីក្រុង ផាមមីរ៉ា , បាមីយាំ និងតំបន់បេតិកភណ្ឌជាច្រើនទៀត។ ប៉ុន្តែទោះបីជាតំបន់ទាំងអស់នោះ ស្ថិតនៅក្នុងបញ្ជីបេតិកភណ្ឌក៏ដោយ ក៏ត្រូវបានបំផ្លាញដោយសារសង្គ្រាម និងពួកក្រុមអីស្លាមដែរ។

អំឡុងពេលសង្គ្រាមស៊ីវិលក្នុងប្រទេសស៊ីរីដែលចាប់ពីឆ្នាំ ២០១១ ទីក្រុងអាឡប៉ូ បានគ្រប់គ្រងដោយក្រុម ISIS នឹងបានបំផ្លាញសំណង់ជាច្រើនដោយសារសង្គ្រាម ដែលធ្វើឱ្យរូបបដិមាសំខាន់ៗជាច្រើននៅតាមប្រាសាទក្នុងក្រុង ក្លោងទ្វារចូលក្រុង ជញ្ជាំងកំពែងជា

[៥] https://www.bbc.com/news/world-middle-east-18957096

[៦] https://whc.unesco.org/en/list/23

ដើមៗ នៅក្នុងឆ្នាំ ២០១២ ទីក្រុងនេះត្រូវបានបំផ្លាញយ៉ាងខ្លាំង ដោយសារការបំផ្ទុះគ្រាប់បែក និងធ្វើឲ្យអាគារថ្មី ៗជាច្រើនត្រូវបានកំទេចផងដែរ។[៧]

តាមរយៈការសិក្សាពីស្រទាប់ដីនៅក្នុងទីក្រុងនេះ បានបង្ហាញថា ស្រទាប់ចាស់ជាងគេគឺនៅស.វ.ទី២០មុនគ.ស. រហូតដល់បច្ចុប្បន្ន។ នៅទីក្រុងនេះ គឺមានការគ្រប់គ្រងច្រើនសម័យកាល តាំងពីសម័យ ហិតិ រហូតដល់អាណាចក្រអូតូម៉ង់ ប៉ុន្តែសំណង់ស្ថាបត្យកម្មបុរាណទាំងនោះ ក៏ត្រូវបានបំផ្លាញដោយសារសង្គ្រាមស៊ីវិលនៅក្នុងប្រទេសស៊ីរី៕




រូបលេខ១ ៖ ផែនទីនៃប្រទេសស៊ីរី , ទីក្រុងអាឡេប៉ូ

ប្រភព៖ Istock

[៧] https://www.bbc.com/news/world-middle-east-18957096

អត្ថបទដោយ៖ អេង តុលា



រូបលេខ២ និង ៣ ៖ ទីក្រុងអាឡេប្ប៉ូបុរាណ មើលពីខាងលើ

ប្រភព៖ Gaudian





រូបលេខ២៤ ៖ ទីក្រុងអាឡេប្ប៉ូបុរាណ

ប្រភព៖ Unesco



រូបលេខ២៥ ៖ ព្រះវិហារក្នុងទីក្រុង អាឡេប្ប៉ូ

ប្រភព៖ Unesco

អត្ថបទដោយ៖ អេង តុលា




រូបលេខ៦ និង ៧ ៖ ទីក្រុងអាឡេប្ប៉ូអំឡុងពេលសង្គ្រាម

ប្រភពៈ BBC



ឯកសារយោង

https://whc.unesco.org/en/list/21/gallery/&maxrows=74

https://www.bbc.com/news/world-middle-east-18957096

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ អេង តុលា